សមាគមអាដហុក
ADHOC

# បរិយាកាសនយោបាយការបោះឆ្នោត២០២២



មុនពេលបោះឆ្នោត  អំឡុងពេលបោះឆ្នោត  ក្រោយពេលបោះឆ្នោត ក្រុមប្រឹក្សាឃុំ/សង្កាត់ ៥-មិថុនា-២០២២

**ភ្នំពេញ  ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០២២**

Address: #3, St 158 Ouknha Trorung Kang, Boeng Raing, Saun Penh, Phnom Penh
Tel: (+855-23) 218 553/210 518/990 544
P.O Box: 1024 – P.O Box 20 at CCC
E-mail: info@adhoccambodia.org
Website: www.adhoccambodia.org
Facebook: www.facebook.com/adhoccam
Twitter: www.twitter.com/adhoccam

# មាតិកា


I. សេចក្តីផ្តើម ........ 3

II. ឫសគល់ការបង្ក្រាប-ការរឹតត្បឹត សេរីភាពនយោបាយ ........ 5

III. មុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទី៥ ........ 6

១. គំរាមឲ្យលាឈប់ពីបញ្ជីឈរឈ្មោះបេក្ខភាពគណបក្ស ........ 7

២. រារាំងការលើកស្លាកសញ្ញាគណបក្ស ........ 10

៣. បំផ្លាញស្លាកសញ្ញាគណបក្ស ........ 11

៤. គំរាមកំហែងតាមប្រព័ន្ធតុលាការ ........ 12

៥. ករណីរឹតត្បិតសេរីភាពជួបប្រជុំ-ករណីលុបឈ្មោះចេញពីបញ្ជីបេក្ខភាព ........ 13

IV ក្របខណ្ឌគតិយុត្តិ ........ 16

V. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ........ 17

V. ឧបសម្ព័ន្ធ ........ 19

## I. សេចក្តីផ្តើម

សេរីភាពនយោបាយ ជាកត្តាដ៏សំខាន់សំរាប់ឆ្លុះបញ្ចាំង អំពីតថភាពសង្គម និងបរិយាកាសនៃការអនុវត្តន៍-ការប្រើប្រាស់លទ្ធិប្រជាធិបតេយ្យ[1]-នីតិរដ្ឋ សិទ្ធិមនុស្សជាមូលដ្ឋាន ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដូចមានចែងក្នុង រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ពិសេសជំពូកទី៣ អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ។

ចាប់តាំងពីក្រោយការរំលាយគណបក្សសង្គ្រោះជាតិ យើងសង្កេតឃើញថា ការរឹតត្បិត និងគំរាមកំហែង សេរីភាពនយោបាយ នៅក្នុងប្រទេសកម្ពុជាមានការកើនឡើងគួរឲ្យកត់សំគាល់ ជាមួយគ្នានេះដែរ ចំពោះស្ថានភាពនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណិតទី៥ ឆ្នាំ២០២២[2]( ថ្ងៃទី៥ ខែមិថុនា )ថ្មីៗកន្លងមកនេះ ក៏យើងបានរកឃើញនូវភាពមិនប្រក្រតីជាច្រើន ទាំងនៅមុនពេលបោះឆ្នោត កំឡុងពេលបោះឆ្នោត និងក្រោយពេលបោះឆ្នោត ដែលភាពមិនប្រក្រតីទាំងនេះវានឹងនាំឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ដំណើការប្រជាធិបតេយ្យ-នីតិរដ្ឋ ហើយដែលអាចនឹងជះឥទ្ធិពលមិនល្អដល់ការរៀបចំបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧[3] ដែលនឹងប្រព្រឹត្តនៅថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣ ខាងមុខនេះថែមទៀតផង ។

មានកត្តាជាច្រើនជា ឧបស័គ្គ រារាំង និងបណ្តាលឲ្យមានការបង្ក្រាប ក្នុងការប្រើប្រាស់ សេរីភាពនយោបាយ ដូចជា៖ ឧបស័គ្គក្នុងការអនុវត្តន៍ច្បាប់ និងគោលនយោបាយ និន្នាការនយោបាយដែលនាំឲ្យមានការរើសអើងអ្នកមានទស្សនៈផ្ទុយ ការអនុវត្តន៍ស្តង់ដាពីរក្នុងប្រព័ន្ធតុលាការ ការប្រើប្រាស់កងកម្លាំងនគរបាលនិងមន្ត្រីរាជការមុខងារសាធារណៈពាក់ព័ន្ធ មិនមានអព្យាក្រិត្យភាព តាមនីតិវិធី និងប្រព័ន្ធផ្សព្វផ្សាយមិនឯករាជ្យ ។ ឥទ្ធិពលនៃការបែកបាក់វប្បធម៌សន្ទនា នាំឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរដល់លំហរសេរីភាពនយោបាយដូចជា មានការរឹតត្បឹត ការបង្ក្រាប ការចាប់ខ្លួន-ឃុំខ្លួន ការវាយដំបង្ករបួសស្នាម តាមដងផ្លូវសាធារណៈ ការស្លាប់យុវជនជាសកម្មជនគណបក្សជំទាស់ ជាពិសេសឈានដល់ការរំលាយគណបក្សសង្គ្រោះជាតិ ក្នុងឆ្នាំ២០១៧[4] ។

**នៅមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណិតទី៥(៥-មិថុនា-២០២២)៖** ចន្លោះខែមករានិងមិថុនា យើងសង្កេតឃើញមានសកម្មជនគណបក្សត្រូវបានស្លាប់ដោយគ្មានមូលហេតុ និងមានមន្ទិលសង្ស័យដូចជាករណី៖ លោក ជឿន សារិម អនុប្រធានប្រតិបត្តិគណបក្សភ្លើងទៀនខណ្ឌច្បារអំពៅ ដែលអាជ្ញាធរអះអាងថា ស្លាប់ដោយសារគ្រោះថ្នាក់ចរាចរនៅស្រុកត្រាំកក់ខេត្តតាកែវ និងករណីបេក្ខជនឈរឈ្មោះគណបក្សភ្លើងទៀន នៅស្អាងខេត្តកណ្តាល ត្រូវជនមិនស្គាល់មុខលួចវាយប្រហារពីក្រោយទាំងកណ្តាលថ្ងៃ ករណីចាប់ឃុំខ្លួនលោកសៀមភ្លុក ស្ថាបនិកគណបក្សបេះដូងជាតិ ពីបទក្លែងបន្លំ និងប្រើប្រាស់លិខិតក្លែង ករណីមន្ត្រីជាន់ខ្ពស់នគរបាល(ឧត្តមសេនីយ៍ឯក)ទះកំភ្លៀងលោក អេង ស្រួយ គ្រូបង្រៀនអង្គភាពក្រុមប្រឹក្សាអភិវឌ្ឍន៍គ្រូនគរបាលជាតិ និងជាប្រធានក្រុមការងារគណបក្សភ្លើងទៀនខេត្តត្បូងឃ្មុំ ដោយមូលហេតុមាននិន្នាការនយោបាយបក្សផ្សេង ។ យោងតាមការអង្កេតបានបង្ហាញថា មានករណីមិនប្រក្រតីចំនួន៨១ បានកើតឡើងក្នុង១៧ខេត្ត ៥០ស្រុក-ក្រុង ៦០ឃុំ-សង្កាត់ ផ្សេងៗគ្នា ដែលករណីទាំងនោះមានដូចជា: គំរាមកំហែងតាមរយៈប្រព័ន្ធតុលាការ បដិសេធ-លុបឈ្មោះបេក្ខជនចេញពីបញ្ជីឈរឈ្មោះគណបក្ស គំរាម(តាមបណ្តា

---

1 លទ្ធិប្រជាធិបតេយ្យ និងការបោះឆ្នោត(Democracy and Election “UNTAC 1992”): https://www.un.org/en/global-issues/democracy

2 ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណិតទី៥ ឆ្នាំ២០២២ https://www.nec.gov.kh/khmer/content/2419

3 កាលបរិច្ឆេទបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ https://www.rfa.org/khmer/news/politics/nec-announces-the-date-of-the-general-election-in-2023-07012022041634.html

4 VOA-17 វិច្ឆិកា២០១៧ https://khmer.voanews.com/a/supreme-court-dissolves-cnrp/4119029.html

ញសង្គម)-បង្ករបួសស្នាម គំរាមឲ្យលាឈប់ពីបញ្ជីឈរឈ្មោះបេក្ខភាពគណបក្ស បំផ្លាញស្លាក សញ្ញាគណបក្ស រារាំងការលើកស្លាកសញ្ញាគណបក្ស និងរឹតត្បិតសេរីភាពជួបជុំសកម្មជនគណបក្ស ។

**នៅអំឡុងពេលការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណិតទី៥(៥-មិថុនា-២០២២)[5]៖** នៅអំឡុងពេលបោះឆ្នោត មានភាពមិនប្រក្រតីមួយចំនួន ដូចជាៈ រារាំងអ្នកសង្កេតការណ៍ មិនឲ្យថតដំណើរការរាប់សន្លឹកឆ្នោត មានការបិទច្រកទីតាំងការិយាល័យ បិទទ្វារបង្អួចការិយាល័យ ក្នុងពេលរាប់សន្លឹកឆ្នោត ការបង្ហាញវត្តមានអាជ្ញាធរមូលដ្ឋានដូចជា មេភូមិ ឃុំ នគរបាលប៉ុស្តិ៍ អង្គុយខាងមុខការិយាល័យបោះឆ្នោតចាំកត់ឈ្មោះអ្នកមកបោះឆ្នោត ។

**នៅក្រោយការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ/សង្កាត់ អាណិតទី៥(៥-មិថុនា-២០២២)៖** ឃើញមានព្រឹត្តិការណ៍កើតឡើងមួយចំនួនដូចជាៈ ការបន្តចាប់ឃុំខ្លួនសកម្មជននយោបាយ ការប្រកាសផ្តន្ទាទោសអ្នកនយោបាយ និងសកម្មជនសិទ្ធិមនុស្សទ្រង់ទ្រាយធំរហូតដល់ចំនួន៦១នាក់ ការប្តឹងលោក សុន ឆ័យ ថ្នាក់ដឹកនាំគណបក្សភ្លើងទៀនទៅតុលាការដោយគណបក្សប្រជាជនកម្ពុជា និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពាក់ព័ន្ធបទបរិហាកេរ្តិ៍មេឃុំចំណារលើខេត្តកំពង់ធំ ទើបជាប់ឆ្នោតថ្មី ត្រូវបានចាប់ខ្លួនបញ្ជូនទៅតុលាការដោយចោទពីបទប្លន់ កាលពីជាងដប់ឆ្នាំមុន ការលុបឈ្មោះចៅសង្កាត់រង ទើបជាប់ឆ្នោតនៅសង្កាត់ច្បារអំពៅ ការលបវាយអនុប្រធានក្រុម ការងារគណបក្សភ្លើងទៀន ខណ្ឌពោធិ៍សែនជ័យ និងការកោះហៅជំទប់ទី២ គណបក្សភ្លើងទៀនម្នាក់ ដោយតុលាការខេត្តត្បូងឃ្មុំ ឲ្យចូលបំភ្លឺពីបទបរិហារកេរ្តិ៍ ។ មកទល់ពេលនេះ មានសកម្មជនសង្គម សកម្មជននយោបាយ ចំនួន៤០នាក់[6]ហើយដែលត្រូវជនមិនស្គាល់មុខ បង្កហិង្សាបណ្តាលឲ្យរងរបួសធ្ងន់ធ្ងរ ជនរងគ្រោះខ្លះស្លាប់ ខ្លះធ្លាក់ខ្លួនពិការ ដោយមានការលួចវាយប្រហារពីក្រោយខ្នង ហើយភាគច្រើនអាជ្ញាធរមិនបានចាប់ខ្លួនជនដៃដល់យកមកផ្តន្ទាទោសតាមច្បាប់នោះទេ ។ លើសពីនេះទៀត អស់រយៈពេលជិត២ខែ (គិតត្រឹមថ្ងៃទី២១ ខែសីហា ឆ្នាំ២០២២) ក្រោយពី ការប្រកាសសុពលភាពចូលកាន់តំណែង ក្រុមប្រឹក្សាឃុំ/សង្កាត់ មកពីគណបក្សភ្លើងទៀនប្រមាណ៣០% មិនទាន់ទទួលបានការបែងចែកតួនាទីភារកិច្ច មានសម្លៀកបំពាក់ឯកសណ្ឋាន កន្លែងអង្គុយធ្វើការនៅឡើយទេ ។

**គោលបំណងរបាយការណ៍៖** ដើម្បីចូលរួមចំណែកលើកកំពស់លទ្ធិប្រជាធិបតេយ្យ-នីតិរដ្ឋបើកលំហរសេរីភាពនយោបាយឲ្យបានទូលំទូលាយ ដូចមានចែងក្នុងច្បាប់ជាធរមាន ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ដើម្បីឆ្លើយតបគោលបំណងនេះ** យើងគួរតែ ចូលរួមឃ្លាំមើលការអនុវត្តន៍បរិយាកាសសង្គមជាក់ស្តែងដូចមានសំនួរលើកឡើងថា៖ តើលំហរសេរីភាពនយោបាយ នៅក្នុងសង្គមកម្ពុជា បច្ចុប្បន្នមានភាពល្អប្រសើរកម្រិតណា? ជាពិសេសព្រឹត្តិការណ៍មុនពេលបោះ អំឡុងពេលបោះឆ្នោត ក្រោយពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២កន្លងមកនេះ តើមានអព្យាក្រឹត្យភាព មានភាពស្មើគ្នាចំពោះការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ការអនុវត្តន៍ច្បាប់ និងគោលនយោបាយ គ្មានការរើសអើងចំពោះអ្នកមានទស្សនៈផ្ទុយ ?

---

[5] AFREL-10 June 2022: https://anfrel.org/preliminary-summary-report-on-situation-of-election-process-on-the-voting-and-counting-day/

[6] RFA-15 Aug 2022: https://streamer1.rfaweb.org/stream/KHM/KHM-2022-0814-1230.mp3

**សារៈសំខាន់របាយការណ៍៖** បង្ហាញឲ្យឃើញពីតថភាពសង្គមបច្ចុប្បន្ន ក្នុងការអនុវត្តន៍-ការប្រើប្រាស់ព្រមទាំងចូលរួមចំណែកក្នុងការស្វែងរកវិធីសាស្ត្រដោះស្រាយឧបសគ្គរាំង ដែលនាំឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់លំហរសេរីភាពនយោបាយ ដើម្បីប្រទេសកម្ពុជាដើរតាមគន្លងលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋពិតប្រាកដ។

**វិធីសាស្ត្រ៖** របាយការណ៍នេះ ត្រូវបានរៀបចំឡើងដោយប្រមូលព័ត៌មាន តាមរយៈរបាយការណ៍អង្កេត និងប្រមូលព័ត៌មានរបស់មន្ត្រីសម្របសម្រួល ប្រចាំការិយាល័យ សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) ទាំង១៧ខេត្ត-ក្រុង មានវិសាលភាពទូទាំងប្រទេស ហើយឆ្លងកាត់ការវិភាគ និងបញ្ចូលទិន្នន័យ នៅស្នាក់ការកណ្ដាលភ្នំពេញ ព្រមទាំងចុះទៅពិនិត្យប្រមូលព័ត៌មានបន្ថែម ដល់ទីកន្លែងកើតហេតុដោយផ្ទាល់ពីសំណាក់មន្ត្រីសរសេររបាយការណ៍ ។ ព័ត៌មានប្រមូលបានមួយចំនួន បានយកមកផ្ទៀងផ្ទាត់ជាមួយ និងព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយ ដែលអាចទុកចិត្តបាន ហើយព័ត៌មានទាំងនោះ បានដកស្រង់សំដីរបស់អ្នកនាំពាក្យ ថ្នាក់ដឹកនាំ និង/ឬ បុគ្គលិករបស់សមាគមអាដហុកផ្ដល់កិច្ចសម្ភាសន៍ ។

ការសរសេររបាយការណ៍ជាលក្ខណៈវិភាគ និងសង្ខេបអត្ថន័យសំខាន់ៗពេញលេញ បង្ហាញពីគោលរឿងនៃបញ្ហា មូលហេតុ និងនីតិវិធីដោះស្រាយ របស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ហើយចំពោះរបាយការណ៍ករណីពេញលេញទាំងស្រុង មានតម្កល់ទុកនៅការិយាល័យកណ្ដាល របស់សមាគមអាដហុកព្រមទាំងរក្សាទុកក្នុងទិន្នន័យសុវត្ថិភាពអេឡិចត្រូនិច ។

## II. ឫសគល់ការបង្ក្រាប-ការរឹតត្បិត សេរីភាពនយោបាយ

ពាក្យថា៖ "លទ្ធិប្រជាធិបតេយ្យ និង នីតិរដ្ឋ" នៅក្នុងសង្គមបច្ចុប្បន្ន ត្រូវបានគេយកមកប្រើ និងនិយាយចាំមាត់ ដោយជួនកាល មានតាក់តែងជាឃ្លាឃ្លោង ចុងជួន ដែលពោរពេញទៅដោយអត្ថន័យ-អត្ថរស ធ្វើឲ្យអ្នកស្ដាប់ជក់ចិត្តស្លុងអារម្មណ៍ដោយមានភាពជឿជាក់។ ទន្ទឹមនេះ បើយើងក្រឡេក មកមើលតថភាពក្នុងសង្គមបាននឹងកំពុងបិតបាំងជាតុពិតនៃការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ មិនគ្រប់លក្ខណៈ[7] គឺគ្រាន់ដើម្បីបន្លំ បិទបាំងភ្នែកសាធារណៈ និងសហគមន៍អន្តរជាតិប៉ុណ្ណោះ ។ ការពិតដែលនៅពីក្រោយវាំងននៃការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ គឺកំពុងមានការគំរាមកំហែង និងរឹតត្បិតខ្លាំង ជាពិសេសចំពោះលំហរសេរីភាពនយោបាយ ជុំវិញព្រឹត្តិការណ៍បោះឆ្នោតឃុំ-សង្កាត់អាណិតទី៥ កន្លងមកនេះ ដែលអាចកំណត់អត្តសញ្ញាណ និងឫសគល់បញ្ហាបណ្ដាលមកពី៖ មានឧបសគ្គក្នុងការអនុវត្តន៍ច្បាប់ និង គោលនយោបាយនិន្នាការនយោបាយ ដោយរើសអើងអ្នកមានទស្សនៈផ្ទុយ ការអនុវត្តន៍ស្តង់ដាពីរ ក្នុងប្រព័ន្ធតុលាការ ការប្រើប្រាស់កងកម្លាំងប្រដាប់អាវុធមិនមានអព្យាក្រិត្យភាពតាមនីតិវិធី និងប្រព័ន្ធផ្សព្វផ្សាយខ្វះឯករាជ្យភាព ។ ហើយឫសគល់បញ្ហាទាំងអស់នេះ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ដំណើរការ នៃការរីកលូតលាស់លទ្ធិប្រជា - ធិបតេយ្យ និងនីតិរដ្ឋក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាកត្តាបង្កឲ្យមានភាពរីកវរសង្គម នាំឲ្យមានភាពលំអៀងធ្លាក់ចុះយុត្តិធម៌សង្គម ដូចជាយុត្តិធម៌ផ្លូវចិត្ត យុត្តិធម៌ផ្លូវច្បាប់ និងការអនុវត្តច្បាប់របស់មន្ត្រីយុត្តិធម៌មួយចំនួនតែងតែប្រើវិធីសាស្ត្រលួងលោម គំរាមកំហែង ចោទប្រកាន់ ចាប់ខ្លួន ឃុំខ្លួន និងលាបពណ៌អ្នកមានទស្សនៈផ្ទុយ ។ កត្តាទាំងនេះហើយ ដែលនាំឲ្យមានការដាក់ទណ្ឌកម្មសេដ្ឋកិច្ច របស់សហគមន៍អឺរ៉ុបក្នុងការដកអ៊ីប៊ីអេ (EBA) ២០% កន្លងមក ហើយដែលត្រូវគេមើលឃើញថា មានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់សេដ្ឋ

[7] មានន័យថា៖ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ មាននៅតែលើក្រដាស់ នៅលើបបូរមាត់អ្នកនយោបាយមានអំណាចដែលបានរៀបចំតាក់តែងឡើងយ៉ាងល្អឥតខ្ចោះទុកសំរាប់ និយាយប្រាប់សាធារណៈជន និងអន្តរជាតិលឺឬមើលតែប៉ុណ្ណោះ ប៉ុន្តែជាតុពិតនៃការអនុវត្តន៍មានភាពផ្ទុយគ្នាស្រឡះ។

កិច្ចសង្គម-សេដ្ឋកិច្ចគ្រួសារ ដូចជាការបាត់បង់ការងារធ្វើ និងចំណាកស្រុកជាដើម ។ លើសពីនេះទៀត ក៏បានធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តសិទ្ធិរបស់ប្រជាពលរដ្ឋដែលត្រូវបានធានាដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ ពិសេសធ្វើឲ្យពលរដ្ឋមួយចំនួនបាក់ស្បាត រហូតដល់ភ័យខ្លាចមិនហ៊ាននិយាយស្តីអ្វីទាំងអស់ មិនហ៊ានចូលរួមក្នុងសកម្មភាពសង្គម និងជាពិសេសសកម្មភាពនយោបាយ ។

### III. មុនការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទី៥ (ចន្លោះខែមករា-ឧសភាឆ្នាំ២០២២)

សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ខែមិថុនា ឆ្នាំ២០២២កន្លងមកនេះ មានគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតចំនួន១៧[8] ដែលក្នុងនោះ គណបក្សប្រជាជនកម្ពុជាដាក់បេក្ខភាពឈរឈ្មោះទូទាំងប្រទេស និងបន្ទាប់មកគណបក្សភ្លើងទៀន ។

យោងតាមការអង្កេត និងទទួលពាក្យបណ្តឹងបានបង្ហាញឲ្យឃើញថា ៖ នៅក្នុងឆមាសទី១ ដើមឆ្នាំ២០២២នេះលំហរសេរីភាពនយោបាយ កាន់តែបន្តរួមតូច រឹតត្បិតយ៉ាងខ្លាំង ចំពោះអ្នកដែលចូលរួមជីវភាពនយោបាយដោយសន្តិភាព ។ កំណើនយ៉ាងខ្លាំង គួរឲ្យកត់សំគាល់ ចំពោះការបង្ក្រាប ការរើសអើង ការលាបពណ៌ ការគំរាមកំហែងចាប់ខ្លួន-ឃុំខ្លួន សកម្មជននយោបាយ ដែលមាននិន្នាការផ្ទុយ ជាពិសេសអាជ្ញាធរមូលដ្ឋាននៅតែរិះរកគ្រប់វិធីសាស្រ្ត ដើម្បីធ្វើការរារាំង គំរាមកំហែង បំភិតបំភ័យ ដល់សកម្មភាពជួបប្រជុំសមាជិកគណបក្ស សកម្មភាពលើកស្លាកសញ្ញាគណបក្សនយោបាយ គំរាមកំហែងសកម្មជនឈរឈ្មោះជាបេក្ខភាពបោះឆ្នោតឃុំ-សង្កាត់ឲ្យដាក់ពាក្យលាឈប់ពីបញ្ជីឈ្មោះគណបក្ស បដិសេធ និងលុបឈ្មោះបេក្ខភាពចេញពីបញ្ជីគណបក្ស ព្រមទាំងប្រព័ន្ធតុលាការចាប់ឃុំខ្លួន ដើម្បីគំរាមកំហែងសកម្មជនគណបក្សទៀតផង ។ ជាពិសេសរបកគំហើញ ការរឹតត្បិតសេរីភាពនយោបាយចំនួន៨១ករណី (៧៨ករណីគណបក្សភ្លើង ទៀន និង០៣ករណីគណបក្សខ្មែរស្រលាញ់ជាតិ) ដែលបានកើតឡើងជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា តាមបណ្តាឃុំ-សង្កាត់ចំនួន៦០ នៃស្រុក-ខ័ណ្ឌចំនួន៥០ ស្ថិតនៅក្នុងខេត្តចំនួន១៧ ។




[8] https://www.nec.gov.kh/khmer/content/5606

## ១. គំរាមឲ្យលាឈប់ពីបញ្ជីឈរឈ្មោះបេក្ខភាពគណបក្ស




ករណីចំនួន៣៥ (៤៣នាក់) ស្ថិតនៅ១៦ខេត្ត ផ្សេងៗគ្នា ដែលមានការបំភិតបំភ័យគំរាមកំហែង បេក្ខជនឲ្យដាក់ពាក្យសុំលាឈប់ពីបេក្ខភាពឈរឈ្មោះបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ និងឈប់ពីអ្នកសង្កេតការណ៍ ឲ្យគណបក្សភ្លើងទៀន និងគណបក្សខ្មែរស្រលាញ់ជាតិ ។

**២. រូបភាពគំរាមកំហែង ធ្វើដោយអាជ្ញាធរមូលដ្ឋាន៖** តាមវិធីសាស្ត្រថតចម្លងបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោតក្រោយពេលអ្នកតំណាងប្រតិបត្តិគណបក្ស យកបញ្ជីនោះទៅធ្វើការបញ្ជាក់នៅសាលាឃុំ និងពិនិត្យមើលរូបថត និងឈ្មោះបេក្ខជនឈរឈ្មោះនៅគណកម្មការបោះឆ្នោតឃុំ៖

- ទៅដល់ផ្ទះបេក្ខជនឈរឈ្មោះគណបក្ស៖ បើមិនជួបសាមីខ្លួនទេ និយាយគំរាម-បំភិតបំភ័យ ផ្ដាំផ្ញើតាមក្រុមគ្រួសារដូចជា ម្ដាយ ឬ/និង ប្រពន្ធកូន (ទំព័រទី៨ ខេត្តសៀមរាប)។
- ទៅដល់ផ្ទះបេក្ខជនឈរឈ្មោះគណបក្ស៖ បង្ខំឲ្យយកអត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ ដើម្បីថតទុក(ក្នុងទូរស័ព្ទដៃ) ដោយមិនប្រាប់មូលហេតុនៃការថតនោះ។
- មេភូមិ និង/ឬ ប្រជាការពារភូមិ តាមឃ្លាំមើលដល់ផ្ទះជាញឹកញាប់ និងគ្រប់សកម្មភាព។
- ទូរស័ព្ទគំរាមឲ្យដកចេញពីតួនាទី៖ ការិយាល័យធម្មការ និងសាសនាស្រុកចិត្របុរី ខេត្តក្រចេះទូរស័ព្ទទៅគំរាម ព្រះចៅអធិការវត្តអន្លង់រៀន (ទំព័រទី៨ ខេត្តក្រចេះ)។
- កោះហៅឲ្យទៅជួបនៅសាលាឃុំ និងស្នាក់ការគណបក្សប្រជាជនកម្ពុជា ឃុំ ។
- ថតរូបពេលទទួលអំណោយ-ទទួលថវិកា២ម៉ឺនរៀល ឬ៥ម៉ឺនរៀល ហើយយករូបថតនោះ ដើម្បីគំរាមកំហែងមិនឲ្យបោះឆ្នោតឲ្យគណបក្សដែលខ្លួនពេញចិត្ត ។
- បង្ខំឲ្យស្បថបោះឆ្នោតឲ្យគណបក្សរបស់ខ្លួន (គណបក្សចែកអំណោយ) នៅពេលទទួលអំណោយ-ទទួលថវិកា ។
- ជិះម៉ូតូកៀរផ្លូល ប្រើដំបងវាយ ឬ/និង គប់ដុំថ្មចូលគេហដ្ឋាន

៦. មូលដ្ឋានដែលអាជ្ញាធរប្រើប្រាស់ដើម្បីគំរាមកំហែងឲ្យដាក់ពាក្យលាឈប់ពីបេក្ខភាពឈរឈ្មោះរួមមាន៖

- បញ្ឈប់ការផ្តល់ប្រាក់ឧបត្ថមជនក្រីក្រប្រចាំខែៈ ដែលក្នុងម្នាក់អាចទទួលបានប្រាក់ឧបត្ថម្ភចាប់ពី១០ម៉ឺនរៀលឡើងក្នុងមួយខែ ហើយការឧបត្ថម្ភនេះ បានធ្វើឡើងនៅអំឡុងពេលម៉ឺរាតត្បាតកូវីដ-១៩ ។
- បញ្ឈប់ ឬមិនផ្តល់ប័ណ្ណក្រីក្រ
- កាត់ផ្តាច់អាហាររូបករណ៍
- មិនផ្តល់ប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុៈ មេឃុំឆ្នោត ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង "បើចូលគណបក្សភ្លើងទៀន គេអត់ចេញប្លង់ដីឲ្យទេ " ។
- ជាសមាជិកគណបក្សប្រជាជនកម្ពុជាៈ តាមចម្លើយសកម្មជនទាំងនោះបញ្ជាក់ថាៈ " ពួកគាត់ចូលជាសមាជិកគណបក្សប្រជាជនកម្ពុជាដោយមិនដឹងខ្លួន - គឺមេភូមិបានឲ្យពួកគាត់ចុះឈ្មោះ ដើម្បីទទួលបានប្រាក់ឧបត្ថម្ភជនក្រីក្រប្រចាំខែ តាំងពីអំឡុងពេលកូវីដ-១៩ " ។
- ដេញមិនឲ្យនៅក្នុងភូមិៈ សម្តីរបស់មេភូមិបឹងអំពិល ឃុំស្ពៅ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ។
- គំរាមចាប់ខ្លួន ថ្ងៃក្រោយមានរឿងធំនាំទុក្ខដាក់ខ្លួនៈ សម្តីមេភូមិសេរីវ័ន្ត ឃុំអណ្តើកហែប ស្រុករតនមណ្ឌល ខេត្តបាត់ដំបង។
- ប្រៀបធៀបជីវភាពមានក្រៈ រវាងការដឹកនាំរបស់គណបក្សប្រជាជានកម្ពុជា- មេឃុំសាលាទួល ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ " ផ្ទះខ្ញុំមានឡាន២-៣គ្រឿង មិនរាប់ម៉ូតូផង " ។
- ដកឈ្មោះចេញពីគ្រូកិច្ចសន្យាៈមេប៉ុស្តិ៍រដ្ឋបាលជប់តាត្រាវ ឃុំជប់តាត្រាវ ស្រុកអង្គធំ ខេត្តសៀមរាប។
- ប្រយ័ត្នមានរឿងអីគេមិនរកខុសត្រូវឲ្យទេថ្ងៃក្រោយ និងពេលមានអំណោយគេមិនចែកឲ្យទេ។
- ចូលគណបក្សភ្លើងទៀននាំឲ្យគេស្អប់ មិនបានសុខ ថ្ងៃក្រោយនាំតែមានបញ្ហា។
- លាឈប់ពីគណបក្សភ្លើងទៀន ហើយមកចូលរួមជាមួយគណបក្សប្រជាជនកម្ពុជា ចាំឲ្យលុយ២-៣ រយដុល្លារអាមេរិកចាយ។

**ខេត្តកំពង់ចាម ស្រុកកំពង់សៀម** (ឃុំគៀនជ្រៃ)៖ សកម្មជន០៤រូប ឈរឈ្មោះបេក្ខភាព បោះឆ្នោតឃុំ-សង្កាត់ គណបក្សភ្លើងទៀន បានចូលទៅជួបលោកស្រីមេឃុំគៀនជ្រៃ នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជា កាលពីថ្ងៃទី០៦-មិនា-២០២២ ។ ក្រោយពីជំនួបជាមួយលោកស្រីមេឃុំគៀនជ្រៃ មានសកម្មជនចំនួន០២នាក់បានសំរេចចិត្តដាក់ពាក្យលាឈប់ពីបញ្ជីបេក្ខភាពគណបក្សភ្លើងទៀន។ ដូចគ្នានេះ ករណីនៅឃុំកោះប្រាក់មានបេក្ខជនឈរឈ្មោះឃុំ-សង្កាត់ គណបក្សភ្លើងទៀន០២ រូប ត្រូវបានមេភូមិកោះប្រាក់ ប្រាប់ឲ្យទៅចុះចូលជាមួយគណបក្សប្រជាជនកម្ពុជាបើពួកគេនៅចង់ទទួលបានប្រាក់ឧបត្ថមប្រចាំខែ និងប័ណ្ណក្រីក្រ។



**ខេត្តបាត់ដំបង ស្រុករតនមណ្ឌល** (ឃុំអណ្តើកហែប)៖ លោកមេភូមិសេរីវ័ន្តបានហៅបេក្ខជនឈរឈ្មោះឃុំគណបក្សភ្លើងទៀនឲ្យទៅជួបនៅផ្ទះ ហើយប្រាប់ថាៈ បើចង់ចេញពីគណបក្សប្រជាជនកម្ពុជាត្រូវដាក់

ពាក្យលាលែង។ បេក្ខជនរូបនោះបានឆ្លើយថាៈ ខ្ញុំមិនដែលដាក់ពាក្យសុំ ចូលជាសមាជិកគណបក្សប្រជាជនកម្ពុជាផង តើឲ្យខ្ញុំដាក់ពាក្យលាលែងដូចម្តេច? មេភូមិបន្ថែមថា បើមិនដាក់ពាក្យលាលែងទេ មិនអាចធ្វើអ្វីបានទេ? បើហ៊ានធ្វើនឹងត្រូវចាប់ខ្លួន! លោកមេភូមិបានបង្ខំឲ្យបំពេញទម្រង់ ផ្តិតស្នាមមេដៃ ដាក់ពាក្យលាលែងនៅផ្ទះលោកមេភូមិ ។ ដើម្បីសុវត្ថិភាព ដោយសារតែការភ័យខ្លាចគាត់បានបំពេញទម្រង់ពាក្យសុំលាឈប់តាមការបង្ខំរបស់មេភូមិ។

**ខេត្តសៀមរាប ស្រុកអង្គរធំ** (ឃុំជប់តាត្រាវ)៖ មេប៉ុស្តិ៍រដ្ឋបាលជប់តាត្រាវបានមកដល់ផ្ទះ ហើយគំរាមកំហែងម្តាយរបស់បេក្ខជនឈរឈ្មោះលំដាប់លេខ១ក្រុមប្រឹក្សាឃុំជប់តាត្រាវថា"ខ្ញុំឃើញកូនបងឯងឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សាឃុំជប់តាត្រាវទៀតហើយ បើបងឯងមិនបានចុះចូលជាមួយកូនទេ ត្រូវទៅរាយការណ៍ជូនលោកមេឃុំទៅថា មិនបានពាក់ព័ន្ធជាមួយកូនទេ បងឯងឃើញស្រាប់ហើយ កូនបងឯងម្នាក់នោះ ត្រូវបានដកចេញពីគ្រូកិច្ចសន្យាដោយសាររឿងគណបក្សហ្នឹងតើ ចំណែកកូនបងឯងម្នាក់នេះទៀត ថ្ងៃណាមួយក៏គេដកចេញពីគ្រូកិច្ចសន្យាដូចគ្នា ។

**ខេត្តឧត្តមានជ័យ ស្រុកត្រពាំងប្រាសាទ** (ឃុំបាក់អន្លង់)៖ មេភូមិស្រែល្អ បានមកដល់ផ្ទះសកម្មជនឈរឈ្មោះគណបក្សភ្លើងទៀន ហើយនិយាយថាៈ ខ្ញុំបានឃើញគេបិទរូបថត ក្នុងបញ្ជីឈ្មោះបេក្ខភាពគណបក្សភ្លើងទៀន នៅគណកម្មាការរៀបចំការបោះឆ្នោតឃុំបាក់អន្លង់...បងឆាប់ទៅដាក់ពាក្យបណ្តឹងសុំដកពាក្យបណ្តឹងចេញពីគណបក្សភ្លើងទៀនជាបន្ទាន់ ប្រយ័ត្នមានរឿងអី គេមិនរកខុសត្រូវឲ្យទេថ្ងៃក្រោយឬគេមានអំណោយគេមិនចែកឲ្យក្រុមគ្រួសារបងឯងទេ!...ឆាប់ទៅដាក់បណ្តឹងលុបឈ្មោះភ្លាម ។

**ខេត្តក្រចេះ ស្រុកចិត្របុរី** (ឃុំកន្ទួត)៖ ប្រធានការិយាល័យធម្មការ និងសាសនាស្រុកចិត្របុរី ទូរស័ព្ទទៅព្រះសង្ឃចៅអធិការវត្តអន្លង់រៀន ស្ថិតនៅភូមិអន្លង់រៀន ហើយគំរាមថាៈ ហេតុអ្វីបានឲ្យអាចារ្យវត្តម្នាក់ឈរឈ្មោះជាបេក្ខភាពបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់? ព្រះអង្គ ត្រូវតែដក អាចារ្យនោះចេញ ប្រសិនបើព្រះអង្គមិនហ៊ានដកទេទុកឲ្យខ្ញុំជាអ្នកដកចេញ ។ ករណីនេះត្រូវបានដោះស្រាយដោយប្រធានការិយាល័យធម្មការ និងសាសនាស្រុកធ្វើការសូមទោស បន្ទាប់ពីប្រធាន និងអនុប្រធានប្រតិបត្តិការគណបក្សភ្លើងទៀនប្រចាំខេត្ត បានធ្វើការទំនាក់ទំនងដោះស្រាយជាមួយប្រធានមន្ទីរធម្មការ និងសាសនាខេត្ត និងគណកម្មាការបោះឆ្នោតខេត្ត ក្រោយទទួលដំណឹងគំរាមកំហែងពីលោកអាចារ្យជាបេក្ខជនឈរឈ្មោះក្រុមប្រឹក្សាឃុំ-សង្កាត់។

**ខេត្តស្វាយរៀង ស្រុកកំពង់រោទិ៍** (ឃុំត្នោត)៖ មេឃុំត្នោតបានដឹកនាំមនុស្សមួយក្រុមរួមមានជំទប់ឃុំ មេភូមិ អនុភូមិ ទៅផ្ទះសកម្មជនឈរឈ្មោះបោះឆ្នោតឃុំគណបក្សភ្លើងទៀន ហើយសួរនាំថាៈ ហេតុអ្វីបានជាឈរឈ្មោះឲ្យគណបក្សភ្លើងទៀន ហើយលោកមេឃុំសួរថាៈ តើមានអចលនទ្រព្យ-មានដីប៉ុន្មានកន្លែង? ប៉ុន្មានហិចតា? បើចូលគណបក្សភ្លើងទៀនគេអត់ចេញប្លង់ដីឲ្យទេ? មិនចេញប័ណ្ណក្រីក្រឲ្យទេ? ហើយពេលមានរឿងហេតុអ្វីកើតឡើងគ្មាននណារកខុសត្រូវឲ្យទេ?

## ២. រារាំងការលើកស្លាកសញ្ញាគណបក្ស




មានករណីចំនួន២០ ស្ថិតនៅ ០៧ខេត្ត ផ្សេងៗគ្នា ដែលមានការរារាំង ហាម ឃាត់មិនឲ្យលើកស្លាកសញ្ញាគណបក្ស ភ្លើងទៀន ទោះជានៅទីកន្លែងឯកជន និងទីកន្លែងសាធារណៈ។ តាមសេចក្ដីរាយការណ៍ រាល់ការលើកស្លាកសញ្ញាគណបក្សគឺសុទ្ធតែរៀបចំធ្វើសេចក្ដីជូនដំណឹងជាមុនទៅអាជ្ញាធរខេត្ត និងអាជ្ញាធរមូលដ្ឋាន ។

**✍ រូបភាពអាជ្ញាធរមូលដ្ឋានប្រើដើម្បីរារាំងហាមឃាត់មិនឲ្យលើកស្លាកសញ្ញាគណបក្សៈ**

- មេឃុំ និង/ឬ មេប៉ុស្តិ៍រដ្ឋបាល បានដឹកនាំមេភូមិ កំលាំងនគរបាលប៉ុស្តិ៍រដ្ឋបាល ចុះទៅដល់ទីកន្លែងដែលក្រុមការងារគណបក្សភ្លើងទៀនកំពុងលើកស្លាកសញ្ញា ហើយសួរនាំរកលិខិតអនុញ្ញាត ។
- កោះហៅម្ចាស់ដី ម្ចាស់ផ្ទះដែលអនុញ្ញាតផ្ដល់ទីតាំងសំរាប់លើកស្លាកសញ្ញា ទៅឆ្លើយបំភ្លឺនៅសាលាឃុំ និងធ្វើកិច្ចសន្យាផ្ដិតមេដៃ។
- អាជ្ញាធរចម្រុះ មាននគរបាលស្លៀកពាក់ឯសណ្ឋាន ក្រុមប្រឹក្សាឃុំ-សង្កាត់ ដឹកនាំដោយអភិបាលរងក្រុង-អភិបាលរងស្រុក ប្រើរថយន្តរដ្ឋ រថយន្តមានស៊ីរ៉ែន ចុះទៅដល់ទីតាំងក្រុមការងារគណបក្សភ្លើងទៀនកំពុងលើកស្លាកសញ្ញា ហើយអ្នកខ្លះដើរចុះដើរឡើង អ្នកខ្លះកាន់ទូរស័ព្ទថតរូបភាព អ្នកឃ្លាំមើលសកម្មភាព។
- កោះហៅក្រុមការងារគណបក្សភ្លើងទៀន ទៅជួបនៅអធិការក្រុង និងឲ្យផ្ដិតមេដៃធ្វើកិច្ចសន្យា មុនពេលលើកស្លាកសញ្ញាគណបក្ស (បន្ទាប់ពីទទួលបានលិខិតជូនដំណឹងអំពីការលើកស្លាកសញ្ញា)។
- អធិការរងក្រុងបញ្ជាឲ្យកម្លាំងនគរបាលរុញច្រាន ដកស្លាកសញ្ញាគណបក្សចេញពីរណ្ដៅវិញ ទាំងនៅពេលក្រុមការងារគណបក្សភ្លើងទៀន កំពុងធ្វើការលើកស្លាកសញ្ញាដាក់ចូលក្នុងរណ្ដៅ។

**✍ មូលហេតុអាជ្ញាធរមូលដ្ឋានប្រើ ដើម្បីរារាំងហាមឃាត់មិនឲ្យលើកស្លាកសញ្ញាគណបក្ស ៖**

- ដីចំណីផ្លូវ អាចប៉ះពាល់ដល់ពេលពង្រីកផ្លូវ ( នៅជិតនោះមានទាំងស្លាកសញ្ញាគណបក្ស និងស្លាកក្រុមហ៊ុនផ្សាយពាណិជ្ជកម្ម )។
- នៅជិតស្ពាននាំឲ្យបាំងក្បាលរថយន្តពេលធ្វើដំណើរឆ្លងកាត់ស្ពាន ។
- គ្មានលិខិតអនុញ្ញាត គ្មានចំណារឯកភាពពីសាលាស្រុក សាលាខេត្ត។
- ដាក់ស្លាកសញ្ញាគណបក្ស មុខរបងវត្តនាំឲ្យមានប៉ះពាល់ដល់សោភណ្ឌភាពទីអារាម ដែលជាកន្លែងគោរពបូជា (នៅជិតបរិវេណនោះក៏មានស្លាកសញ្ញាគណបក្សផ្សេងដាក់បាន)។

**ខេត្តត្បូងឃ្មុំ ស្រុកក្រូចឆ្មា** (ឃុំប៉ើសពីរ)៖ នៅមុខផ្ទះក្នុងបរិវេណដីលំនៅឋានឯកជន ២កន្លែងគឺ ស្ថិតនៅភូមិអំពិល មេភូមិបានមករារាំងហាមឃាត់ មិនឲ្យលើកស្លាកគណបក្សភ្លើងទៀន ដោយមេភូមិបាននិយាយប្រាប់ក្រុមការងារគណបក្សភ្លើងទៀនថាៈ ខ្ញុំ(មេភូមិ) បានទទួលបញ្ជាពីសាលាស្រុក មិនឲ្យលើកស្លាកគណបក្សទេ និងស្លាកសញ្ញាគណបក្សមួយទៀតបានរៀបចំលើកនៅភូមិទួលសម្បត្តិ ត្រូវបានរារាំងហាមឃាត់ ដោយមន្រ្តីប៉ូលីសប៉ុស្តិ៍០២នាក់ ក្នុងសម្លៀកបំពាក់ឯកសណ្ឋាន ពីព្រោះការលើកស្លាកសញ្ញាគណបក្សនេះ មិនទាន់មានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន ។ លើសពីនេះទៀត ស្នែកឡើង ម្ចាស់ផ្ទះទាំងពីរដែលបានអនុញ្ញាតផ្តល់ទីតាំងឲ្យលើកស្លាកសញ្ញា បានទទួលលិខិតអញ្ជើញ ឲ្យចូលឆ្លើយបំភ្លឺនៅសាលាឃុំពាក់ព័ន្ធការអនុញ្ញាតឲ្យដាក់ស្លាកសញ្ញាគណបក្សភ្លើងទៀន នៅមុខផ្ទះរបស់ខ្លួន ។ ក្រោយពីចូលទៅឆ្លើយបំភ្លឺនៅសាលាឃុំមានព័ត៌មានថា មានសមាជិកចំនួន០៧នាក់ បានសុំលាឈប់ចូលរួមនយោបាយជាមួយបក្សភ្លើងទៀន ។

**ខេត្តកំពង់ចាម ស្រុកចំការលើ** (ឃុំតាអុង)៖ មេភូមិតាអុង និងជំទប់ទី១ឃុំតាអុង ព្រមទាំងឃើញមានវត្តមាននគរបាលប៉ុស្តិ៍ និងអធិការរងស្រុក នៅឃ្លាំមើលជិតនោះដែរ បានរារាំងហាមឃាត់ក្រុមការងារគណបក្សភ្លើងទៀនមិនឲ្យលើកស្លាកគណបក្ស ដែលមានទីតាំងនៅចំណុចក្បែរផ្សារតាអុងជិតបង្គោលភ្លើង ស្ថិតនៅភូមិតាអុង ដោយមូលហេតុថា ទីតាំងនេះ អាចនឹងមានការប៉ះពាល់ដល់ ការពង្រីកផ្លូវ (បញ្ជាក់ថាៈ នៅចំណុចនោះ ឃើញមានស្លាកសញ្ញា ក្រុមហ៊ុនផ្សព្វផ្សាយពាណិជ្ជកម្មស្រាបៀរ)។



**ស្រុកអង្គរជ័** (ឃុំជប់តាត្រាវ)៖ ក្រុមអាជ្ញាធរ មានកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាល បានចុះទៅដល់កន្លែង ហើយថតសកម្មភាព និងសួរនាំរកច្បាប់អនុញ្ញាត ក្រុមការងារគណបក្សភ្លើងទៀន កំពុងលើកស្លាកសញ្ញាគណបក្ស ស្ថិតនៅចំណុចភូមិប្រាសាទ ព្រមទាំងគម្រាមចុងកៅមិនឲ្យធ្វើម្ហូប សំរាប់ក្រុមការងារគណបក្សភ្លើងទៀនហូបឡើយ ។

### ៣. បំផ្លាញស្លាកសញ្ញាគណបក្ស

ស្លាកសញ្ញាគណបក្សភ្លើងទៀន និងស្លាកសញ្ញាគណបក្សខ្មែរស្រលាញ់ជាតិ ចំនួន០៨ករណី(កន្លែង) ផ្សេងៗដែលបានកើតនៅក្នុងខេត្ត០៥ គឺខេត្តត្បូងឃ្មុំ០៣ករណី ខេត្តកំពង់ចាម០១ករណី ខេត្តសៀមរាប ០១ករណី ខេត្តស្វាយរៀង០១ករណី ខេត្តព្រះសីហនុ០២ករណី។

**✍ រូបភាពការបំផ្លិចបំផ្លាញស្លាកសញ្ញាគណបក្ស៖**

- ដកផ្តួលចោលនៅជិតកន្លែងរណ្តៅ
- ដុតបំផ្លាញចោល
- ប្រើវត្ថុរឹងៈ ពូថៅ កាំបិត ដែកស្រួច

**✍ អត្តសញ្ញាណអ្នកបំផ្លិចបំផ្លាញស្លាកសញ្ញាគណបក្ស៖**

- ជនមិនស្គាល់អត្តសញ្ញាណ
- អាជ្ញាធរមូលដ្ឋាន និងកំលាំងសមត្ថកិច្ចក្នុងសំលៀកបំពាក់ឯកសណ្ឋាន

- ជនមានសតិមិនប្រក្រតី

**ខេត្តប៉ៃលិន ស្រុកសាលាក្រៅ**(ឃុំស្ទឹងកាច់)៖ ដោយសំអាងថាៈ ការលើកស្លាកសញ្ញាគណបក្សនេះ មិនទាន់មានច្បាប់អនុញ្ញាត អាជ្ញាធរមានគ្នា១០នាក់ ក្នុងសំលៀកបំពាក់ឯកសណ្ឋាននគរបាលខ្លះ និងស៊ីវិលខ្លះ បានមកបំផ្លិចបំផ្លាញដកស្លាកសញ្ញាគណបក្សភ្លើងទៀន ដែលបានដាក់នៅចំហៀងមុខផ្ទះក្នុងបរិវេណលំនៅឋានឯកជន ស្ថិតនៅភូមិផ្សារព្រំដើង យកទៅទម្លាក់ចោលនៅចំហៀងនៃម្ខាងផ្ទះ ចម្ងាយប្រហែល៥ម៉ែត្រ ក្រោយពីក្រុមការងារគណបក្សភ្លើងទៀនដាក់ មិនទាន់បានមួយម៉ោងផង ។ បញ្ជាក់ថាៈ នៅខណៈពេលពួកគេកំពុងធ្វើសកម្មភាពដកស្លាកសញ្ញាគណបក្ស ម្ចាស់ផ្ទះជាស្ត្រីបានឃើញសកម្មភាពនោះហើយធ្វើឲ្យគាត់ភិតភ័យយ៉ាងខ្លាំង ពេលនោះគាត់បានរត់ទៅផ្ទះអ្នកជិតខាងចម្ងាយប្រហែល៤០ម៉ែត្រ ដើម្បីខ្ចីទូរស័ព្ទដើម្បីថតសកម្មភាពដកស្លាកសញ្ញាគណបក្សរបស់ក្រុមនគរបាល ប៉ុន្តែពេលនោះត្រូវបានមនុស្សម្នាក់ក្នុងចំណោម១០នាក់ បានឃើញស្ត្រីនោះ កំពុងថតសកម្មភាពពួកខ្លួន ក៏បានរត់មកដណ្តើមទូរស័ព្ទលុបរូបភាពចោលវិញភ្លាមៗ ហើយរយៈពេលប្រហែលកន្លះម៉ោងក្រោយ ទើបពួកគេបានធ្វើដំណើរចាកចេញទៅ ។




**ស្រុករំដួល** (ឃុំជ្រុងពពេល)៖ ស្លាកបក្សភ្លើងទៀន មួយត្រូវបានជនមានសតិមិនប្រក្រតីប្រើពូថៅកាប់បំផ្លាញជាច្រើនពូថៅ មុខផ្ទះសកម្មជនគណបក្សភ្លើងទៀន ស្ថិតនៅក្នុងភូមិក្រូច ។ គួរបញ្ជាក់ផងដែរថា៖ ជនដដែលនេះដែរ កាលពី៥ឆ្នាំមុន ក៏ធ្លាប់កាប់បំផ្លិចបំផ្លាញស្លាកគណបក្សសង្គ្រោះជាតិម្តងដែរ ។

## ៤. គំរាមកំហែងតាមប្រព័ន្ធតុលាការ

សកម្មជនគណបក្ស បេក្ខភាពឈរឈ្មោះបោះឆ្នោត ឃុំ-សង្កាត់ ត្រូវបានតុលាការកោះហៅឆ្លើយបំភ្លឺ និងបានឃុំខ្លួន ដូចជាករណីនៅខេត្តពោធិសាត់ តុលាការឃុំខ្លួន បេក្ខជនឈរឈ្មោះគណបក្សភ្លើងទៀននៅពន្ធនាគារខេត្តចំនួន០២ករណី ពីបទក្លែងឯកសារ ។ ខេត្តស្ទឹងត្រែងអតីតសកម្មជននយោបាយ គណបក្សសង្គ្រោះជាតិម្នាក់បានចាប់ខ្លួននៅប្រទេសថៃ បញ្ជូនមកឃុំខ្លួននៅប្រទេសកម្ពុជាពីបទប្រើប្រាស់បណ្តាញសង្គមរិះគន់រដ្ឋាភិបាលកម្ពុជា ។ ខេត្តឧត្តមានជ័យ សកម្មជនគណបក្សភ្លើងទៀនម្នាក់ត្រូវបានចាប់ខ្លួនតាមដីកាតុលាការក្រោមបទចោទរួមគំនិតក្បត់ និងបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារខេត្ត ក្រោយមកត្រូវបានតុលាការសំរេចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

**ខេត្តពោធិសាត់ ស្រុកកណ្តៀង**(ឃុំស្រែស្តុក)៖ បេក្ខជនឈរឈ្មោះឃុំស្រែស្តុក ត្រូវបានតុលាការខេត្តពោធិ៍សាត់ ធ្វើការចោទប្រកាន់ និងឃុំខ្លួនពីបទក្លែងឯកសារ ។ គួរបញ្ជាក់ផងដែរថាៈ នៅថ្ងៃទី៧-មីនា-២០២២ បេក្ខជនឈរឈ្មោះឃុំស្រែស្តុកគណបក្សភ្លើងទៀន ម្នាក់ត្រូវបានចាប់ខ្លួនបញ្ជូនទៅប៉ុស្តិ៍ឃុំស្រែស្តុក ដើម្បីសួរនាំ រួចបញ្ជូនបន្តទៅស្នងការដ្ឋានខេត្តពោធិ៍សាត់ រហូតដល់ថ្ងៃទី១១-មិនា-២០២២ និងបញ្ជូនទៅតុលាការខេត្តពោធិ៍សាត់ និងត្រូវបានចោទប្រកាន់ពីបទក្លែងឯកសារ ហើយបានបញ្ជូនបន្តទៅឃុំខ្លួននៅពន្ធនាគារខេត្តពោធិ៍សាត់ ។ ករណីនេះ កើតឡើងថ្ងៃទី៦-មិនា-២០២២ ក្រោយពីបេក្ខជនរូបនេះបានយកបញ្ជីឈ្មោះបេក្ខ

ជនឈរឈ្មោះឃុំគណបក្សភ្លើងទៀនទៅឲ្យមេឃុំបញ្ជាក់ ក្នុងខណៈនោះមានមន្ត្រីប៉ុស្តិ៍បានថតចម្លងបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះឃុំគណបក្សភ្លើងទៀន ចែកឲ្យមន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំស្រែស្ពុក យកចេញទៅ ។ មួយថ្ងៃក្រោយមកមានបេក្ខជនក្នុងបញ្ជីចំនួន០៥នាក់ បានសុំដកឈ្មោះចេញពីបញ្ជីឈ្មោះបេក្ខជនគណបក្សភ្លើងទៀន បើតាមសម្តីម្នាក់ ក្នុងចំណោមប្រាំនាក់បាននិយាយថាៈ " មេឃុំស្រែស្ពុក បានហៅគាត់ឲ្យទៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជាឃុំ ដើម្បីទទួលអំណោយ បន្ទាប់មកឲ្យទៅប៉ុស្តិ៍រដ្ឋបាលឃុំ ដើម្បីធ្វើកំណត់ហេតុប្តឹងបេក្ខជនឈរឈ្មោះមេឃុំគណបក្សភ្លើងទៀន តែគាត់មិនព្រម? " ។

## ៥. ករណីរឹតត្បិតសេរីភាពជួបប្រជុំ-ករណីលុបឈ្មោះចេញពីបញ្ជីបេក្ខភាព

យោងតាមការអង្កេត បានរកឃើញករណីគួរឲ្យកត់សំគាល់ដូចជា **ករណីរឹតត្បិតសេរីភាពជួបប្រជុំ** សកម្មជនគណបក្សនៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ស្ពឺ មានអាជ្ញាធរ ប្រជាការពារភូមិ និងមេឃុំ ក្រុមប្រឹក្សាឃុំគំរាមមិនឲ្យមានការជួបជុំពិភាក្សាពីបញ្ហានយោបាយនៅផ្ទះឯកជន ។ **ករណីបដិសេធ និងលុបឈ្មោះចេញពីបញ្ជីបេក្ខភាពគណបក្ស** ដោយមូលហេតុអក្សរមិនស្អាត ឬមិនចេះអក្សរ ដូចជានៅខេត្តកោះកុង និងខេត្តប៉ៃលិន ។ **ករណីគំរាមសម្លាប់តាមបណ្តាញសង្គម** នៅខេត្តប៉ៃលិនសកម្មជនគណបក្សភ្លើងទៀនបានផាតតាមបណ្តាញសង្គមគំរាមសម្លាប់ ដោយដាក់រូបកាំភ្លើងជាដើម ។

**ករណីរឹតត្បិតសេរីភាពជួបប្រជុំៈ នៅខេត្តកំពង់ស្ពឺ ស្រុកបរសេដ្ឋ**(ឃុំទួលសាលា)ៈ អំឡុងពេលសកម្មជនគណបក្សភ្លើងទៀនកំពុងជួបជុំរៀបចំប្រវត្តិរូបបញ្ជីបេក្ខភាពឈរឈ្មោះក្រុមប្រឹក្សាឃុំទួលសាលា ដើម្បីចូលរួមបោះឆ្នោត ពេលនោះស្រាប់តែមេភូមិធ្លក និងប្រជាការពារ០៥នាក់ បានចុះទៅដល់ផ្ទះហើយគំរាមកំហែងថា : " ធ្វើអ្វីហ្នឹង? ចង់បង្កើតបក្សទៀតម៉េចមិនសុំច្បាប់ពីខ្ញុំជាមេភូមិសិន? មួយសន្ទុះក្រោយមក ឃើញមេឃុំ និងក្រុមប្រឹក្សាឃុំ០៣នាក់ទៀតមកដល់ ហើយស្រែកគំរាមថាៈ ចាប់ពួកវាឲ្យបាន កុំឲ្យវារត់រួច...មេឃុំបន្ថែមទៀតថាៈ អ្នកឯងធ្វើស្អី ម៉េចមិនសុំច្បាប់អាជ្ញាធរភូមិឃុំ ? ចង់ប្រឆាំងផ្តួលរំលំរដ្ឋាភិបាលមែនទេ? ប្រយ័ត្នជាប់គុកបក្សមួយងាប់ហើយមិនរស់វិញផង......ចង់ឲ្យងាប់បក្សមួយទៀតឬ? ក្រោយមកទៀត លោកមេឃុំអមដំណើរដោយប្រជាការពារ បានធ្វើដំណើរមកគំរាមម្ចាស់ផ្ទះថាៈ ហ៊ានអនុញ្ញាតឲ្យគេធ្វើសកម្មភាពនយោបាយដោយមិនមានការយល់ព្រមពីមេភូមិមេឃុំ បើមានរឿងអ្វីម្ចាស់ផ្ទះជាអ្នកទទួលខុសត្រូវចំពោះមុខច្បាប់កុំខ្លាំងប្រយ័ត្នជាប់គុក...ចង់ប្រឆាំងអីទៀតស្រុកគេរីកចំរើនដល់ណាដល់ណីហើយ ក្រោមការដឹកនាំគណបក្សប្រជាជនកម្ពុជា.......ផ្ទះខ្ញុំមានឡាន២-៣គ្រឿង មិនរាប់ម៉ូតូផង......ម៉េចចង់ផ្តួលរំលំរដ្ឋាភិបាលទៅ មិនរួចទេ? ចាប់ពីថ្ងៃនេះទៅមិនឲ្យធ្វើសកម្មភាពអ្វីទាំងអស់ រួមទាំងការលើកស្លាកសញ្ញាគណបក្ស បើហ៊ានធ្វើប្រយ័ត្នជាប់គុក!

**ករណីគំរាមសម្លាប់តាមបណ្តាញសង្គម ៖ នៅខេត្តប៉ៃលិន ក្រុងប៉ៃលិន**(សង្កាត់ប៉ៃលិន)៖ សកម្មជននយោបាយគណបក្សភ្លើងទៀនឈរឈ្មោះសង្កាត់ប៉ៃលិនលំដាប់ទី៣ រស់នៅភូមិប៉ាហ៊ីជើង ត្រូវបានជនមិនស្គាល់អត្តសញ្ញាណផាតមកគំរាមតាមបណ្តាញសង្គម ដោយផ្ញើរូបកាំភ្លើងខ្លីមួយដើមជាមួយសំណេរថាៈ " ទុកបាញ់មនុស្ស " ព្រមទាំងផ្ញើសារជាសម្លេងថា៖ " ទុកបាញ់មនុស្សដែលនិយាយមិនពិត និយាយបំប៉ោងបំផ្លើសក្រុមអ្នកឯងយកភ្លើងទៀនមកដុតគេទៀតហើយ..អ្នកណាជាអ្នករំដោះប៉ៃលិន...អស់ពីភ្លើងទៀនមកសង្គ្រោះជាតិ

ឥឡូវទៅភ្លើងទៀនវិញហើយ គេឲ្យប៉ុន្មាន បានជាខំប្រឹងម្ល៉េះ ” ។ ករណីនេះ ដោយមានការបារម្ភពីសុវត្ថិភាព សាមីខ្លួនក៏បានគេចចេញពីផ្ទះទៅរស់នៅកន្លែងសុវត្ថិភាពជាបណ្ដោះអាសន្នមួយកន្លែង ។

**ករណីបដិសេធ និងលុបឈ្មោះចេញពីបញ្ជីបេក្ខភាពគណបក្ស៖ នៅខេត្តកោះកុង ស្រុកថ្មបាំង**( ឃុំឬស្សីជ្រុំ )





សកម្មជនគណបក្សប្រជាជនកម្ពុជា បានដាក់ពាក្យប្ដឹងជំទាស់ ទៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្ត អំពីបេក្ខភាពឈរឈ្មោះក្រុមប្រឹក្សាឃុំគណបក្សភ្លើងទៀនចំនួន០៥នាក់ ថាមិនចេះអក្សរ ។ ករណីនេះ ប្រធានរដ្ឋបាលស្រុកថ្មបាំងបានគម្រាមផ្ដាំផ្ញើ ទៅការិយាល័យបោះឆ្នោតឃុំឬស្សីជ្រុំថា៖ ប្រសិនបើអ្នកទាំង០៥នាក់នោះ មិនព្រមដកឈ្មោះពីបេក្ខភាពឈរឈ្មោះគណបក្សភ្លើងទៀនទេ ប្រយ័ត្នជួបផលលំបាកនៅថ្ងៃមុខ ។ គណកម្មាធិការជាតិរៀបចំការបោះឆ្នោត បានសម្រេចលុបឈ្មោះបេក្ខជន០៤រូប ចេញពីបញ្ជីឈរឈ្មោះបោះឆ្នោតឃុំ ។

IV **អំឡុងពេលបោះឆ្នោត៖** ឆ្លងតាមការសង្កេត នៅអំឡុងពេលការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទី៥ ថ្ងៃទី៥-មិថុនា-២០២២ ឃើញមានភាពមិនប្រក្រតីមួយចំនួនដូចជា៖

- អាជ្ញាធរ[9]មានវត្តមាន-ឈរនៅមុខបរិវេណការិយាល័យបោះឆ្នោត ហើយចាំកត់ត្រាឈ្មោះអ្នកមកចូលរួមបោះឆ្នោត។
- ប្រជាពលរដ្ឋខកខានមិនបានចូលរួមបោះឆ្នោត ដោយមានការលំបាកក្នុងការរកឈ្មោះ និងរកឈ្មោះមិនឃើញ លើសពីនេះទៀតទិន្នន័យ ក្នុងឯកសារបញ្ជាក់អត្តសញ្ញាណខុសពីទិន្និន័យក្នុងបញ្ជីឈ្មោះបោះឆ្នោត ឬ មិនមានឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឲ្យការបោះឆ្នោត និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ហួសសុពលភាពប្រើប្រាស់ ឬបាត់បង់ ។
- រារាំងអ្នកសង្កេតការណ៍មិនឲ្យចូលសង្កេត និងមិនឱ្យថតដំណើរការ រាប់សន្លឹកឆ្នោតនៅតាមការិយាល័យបោះឆ្នោតភាគច្រើន ។
- ដំណើរការរាប់សន្លឹកឆ្នោតនៅការិយាល័យមួយចំនួន សង្កេតឃើញថា បិទច្រកទីតាំងការិយាល័យ និងបិទទ្វារបង្អួចការិយាល័យរាប់សន្លឹកឆ្នោត ហើយមិនអនុញ្ញាតឱ្យប្រជាពលរដ្ឋមើលការរាប់សន្លឹកឆ្នោត ។
- មន្ត្រីការិយាល័យបោះឆ្នោតមួយចំនួន មិនបានបិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត នៅមុខការិយាល័យបោះឆ្នោត ក្រោយដំណើរការបោះឆ្នោតបានបញ្ចប់ឡើយ ។

---

[9] អាជ្ញាធរគឺសំដៅចំពោះ សមាជិកភូមិ មេភូមិ មេឃុំ ឬចៅសង្កាត់ មន្ត្រីនគរបាលរដ្ឋបាល។

- ការិយាល័យមួយចំនួន មិនបានបំពេញព័ត៌មាន ដែលបានកំណត់ក្នុងច្បាប់ បទបញ្ជា និងនីតិវិធី អំពីលទ្ធផលនៃការរាប់សន្លឹកឆ្នោត សម្រាប់គណបក្សនយោបាយនីមួយៗ នៅក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលត្រូវបិទនៅមុខការិយាល័យបោះឆ្នោត ។

## V ក្រោយពេលបោះឆ្នោត (ចន្លោះថ្ងៃទី១៤ ឧសភា-កញ្ញាឆ្នាំ២០២២)

ឆ្លងតាមការអង្កេតស្ថានភាពក្រោយការបោះឆ្នោតឃុំ-សង្កាត់មានព្រឹត្តិការណ៍នយោបាយធំៗកើតឡើងគួរឲ្យកត់សម្គាល់ក្រោយការបោះឆ្នោតបាន០៩ថ្ងៃដូចជា ៖



កញ្ញា សេង ធារី ពេលសមត្ថកិច្ចចាប់ក្រៀក ក្នុងសំលៀកបំពាក់ជារូបសំណាកអ្នកនាងសេរីភាព នៅថ្ងៃប្រកាសសាលក្រម នៅព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២។ រូបភាព / AFP

- សាលាដំបូងរាជធានីភ្នំពេញ បានប្រកាសសាលក្រមផ្តន្ទាទោស កញ្ញា សេង ច័ន្ទធារី ជាប់ពន្ធនាគារ៦ឆ្នាំ ពីបទចោទរួមគំនិតក្បត់ ក្នុងសំណុំរឿងវិលចូលស្រុករបស់លោក សម រង្ស៊ី កាលពីឆ្នាំ២០១៩ ព្រមទាំងផ្តន្ទាទោសអ្នកនយោបាយ និងសកម្មជនសិទ្ធមនុស្ស ៦១នាក់ ដាក់ឲ្យជាប់ពន្ធនាគារពី៥ឆ្នាំ ខ្លះ៦ឆ្នាំ និងខ្លះទៀត រហូតដល់៨ឆ្នាំ ក្នុងសំណុំរឿង រួមគំនិតក្បត់ និងញុះញង់ ។
- គណបក្សប្រជាជនកម្ពុជា និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានដាក់ពាក្យបណ្តឹង លោក សុន ឆ័យ អនុប្រធានគណបក្សភ្លើងទៀន ដោយចោទលោក សុន ឆ័យ ដែលរិះគន់ពីដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់កន្លងទៅនេះថា ជាអំពើទុច្ចរិតបំភ្លៃខុសការពិត ផ្តល់ព័ត៌មានក្លែងក្លាយ ទម្លាក់កំហុសធ្វើឲ្យប៉ះពាល់កិត្តិយសគណបក្សប្រជាជនកម្ពុជា និងស្ថាប័ន គជប ។
- ការចាប់ខ្លួនមេឃុំទើបជាប់ឆ្នោត ខាងគណបក្សភ្លើងទៀន ។ លោក ញឹម សារ៉ុម ត្រូវបានសមត្ថកិច្ចចាប់ខ្លួនបញ្ជូនទៅតុលាការ ក្នុងពេលកំពុងបំពេញការងារ នៅក្នុងសាលាឃុំចំណាររលើស្រុកសន្ទុកខេត្តកំពង់ធំ ដោយចោទបទប្លន់ ដោយមិនសមហេតុផល កាលពីជាងដប់ឆ្នាំមុន ។ ប៉ុន្តែនៅថ្ងៃបន្ទាប់តុលាការបានអនុញ្ញាតឲ្យនៅក្រៅឃុំវិញ ។
- ការលុបឈ្មោះចៅសង្កាត់រងទី២ សង្កាត់ច្បារអំពៅ១ ជាប់ឆ្នោតខាងគណបក្សភ្លើងទៀន ។ លោក កែវ សុមុនី ត្រូវបានក្រសួងសុខាភិបាលលុបឈ្មោះចេញពីក្រុមបខណ្ឌមន្ត្រីរាជការ ក្រោមហេតុផលថា បានធ្វើខុសវិន័យ ទោះបីជាដឹងថា នៅពេលលោកឈរឈ្មោះជាបេក្ខជនតំណាង គណបក្សភ្លើងទៀន លោកបានសុំអនុញ្ញាត ដោយមានលិខិតសុំច្បាប់ត្រឹមត្រូវទៅអង្គភាពរួចហើយក៏ដោយ ។
- អនុប្រធានក្រុមការងារគណបក្សភ្លើងទៀន ខណ្ឌពោធិ៍សែនជ័យ លោក នល់ ពង្សជិរិទ្ធ ត្រូវក្រុមជនល្មើសជិះម៉ូតូវាយត្រង់ក្បាលឲ្យរបួសធ្ងន់ ។ មកទល់ពេលនេះ មានសកម្មជនសង្គម សកម្មជននយោបាយ ចំនួន៤០នាក់[10]ហើយដែលត្រូវជនមិនស្គាល់មុខ បង្កហឹង្សាបណ្តាលឲ្យរងរបួសធ្ងន់ធ្ងរ ជនរងគ្រោះខ្លះស្លាប់ខ្លះធ្លាក់ខ្លួនពិការ ដោយមានការលួចវាយប្រហារពីក្រោយខ្នង ហើយភាគច្រើនអាជ្ញាធរមិនបានចាប់ខ្លួនជនដៃដល់យកមកផ្តន្ទាទោសតាមច្បាប់នោះឡើយ ។
- តុលាការខេត្តត្បូងឃ្មុំកោះហៅជំទប់ទី២ គណបក្សភ្លើងទៀន លោកស្រី សុខ ស្រីនួន ចូលបំភ្លឺពីបទបរិហារកេរ្តិ៍ជាសាធារណៈតាមបណ្តាញសង្គមហ្វេសប៊ុក ។

[10] RFA-15 Aug 2022: https://streamer1.rfaweb.org/stream/KHM/KHM-2022-0814-1230.mp3

- ប្រមាណ៣០% នៃក្រុមប្រឹក្សាឃុំ/សង្កាត់ មកពីគណបក្សភ្លើងទៀន មិនទាន់ទទួលបានការបែងចែកតួនាទីភារកិច្ច មានសម្លៀកបំពាក់ឯកសណ្ឋាន កន្លែងអង្គុយធ្វើការនៅឡើយទេ ក្រោយពីការប្រកាសសុពលភាពចូលកាន់តំណែងអស់រយៈពេលជិត២ខែ បើគិតត្រឹមសប្តាហ៍ទី៤ សីហា ឆ្នាំ២០២២ ។
- សកម្មជនអតីតគណបក្សសង្គ្រោះជាតិ១៤នាក់ ត្រូវបានអាជ្ញាធរពន្ធនាគារផ្ទេរពីមណ្ឌលអប់រំកែប្រែម១ សង្កាត់ព្រៃសភ្នំពេញទៅពន្ធនាគារត្រពាំងថ្លុងខេត្តត្បូងឃ្មុំ មិនត្រឹមតែប៉ុណ្ណោះសកម្មជន០៣នាក់ត្រូវបានក្រុមបងធំនៅក្នុងពន្ធនាគារ (អ្នកជាប់ឃុំដូចគ្នា) វាយដំទាត់ធាក់ រហូតដល់មានរបួសធ្ងន់ធ្ងរដោយមិនមានការយកចិត្តទុកដាក់ពីក្រុមអាជ្ញាធរពន្ធនាគារឡើយ ។

## VI ក្របខណ្ឌគតិយុត្តិ

| | |
|---|---|
| រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ | - **មាត្រា៣១ (កឋាខ័ណ្ឌទី២):** ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ...។<br>- **មាត្រា៣៤ថ្មី:** ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឲ្យគេបោះឆ្នោត។<br>- **មាត្រា៣៥:** ពលរដ្ឋទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុង ជីវភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ប្រទេសជាតិ។ សេចក្តីស្នើទាំងឡាយណា របស់ប្រជាពលរដ្ឋត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។ |
| ច្បាប់ស្តីពីគណបក្សនយោបាយ | - **មាត្រា៤:** គ្រប់គណបក្សនយោបាយមានសិទ្ធិស្មើៗគ្នា ក្នុងការទទួលបុព្វសិទ្ធិ និងការយកចិត្តទុកដាក់ ដោយស្មើភាពគ្នាពីរាជរដ្ឋាភិបាល និងអាជ្ញាធរគ្រប់ជាន់ថ្នាក់ ។<br>- **មាត្រា៥:** ការចូលជាសមាជិករបស់គណបក្សនយោបាយណាមួយ គឺជាការជ្រើសរើសផ្ទាល់ខ្លួន ដោយសេរីភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប..គ្មានជនណាម្នាក់ ត្រូវបានគេដកហូតសិទ្ធិ ក្នុងការអនុវត្តសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ ឬសិទ្ធិវិជ្ជាជីវៈដោយសារមូលហេតុជននោះជាសមាជិក ឬមិនមែន ជាសមាជិកគណបក្សនយោបាយណាមួយដែលបង្កើតឡើង ដោយស្របច្បាប់នោះទេ ។<br>- **មាត្រា១៥ (កឋាខណ្ឌទី២):** បុព្វជិត មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងកងកំលាំង នគរបាល អាចចូលរួមជាសមាជិកគណបក្សនយោបាយនានាបាន តែមិនត្រូវធ្វើសកម្មភាពគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយឡើយ ។ |
| ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ | - **មាត្រា៦៩.** ស្លាកសញ្ញាគណបក្សនយោបាយអាចលើកនៅទីសាធារណៈ ដោយមានការសម្រេចសម្រួលពីអាជ្ញាធរឃុំ សង្កាត់ផ្អែកលើ |

| | |
|---|---|
| | គោលការណ៍ស្មើភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណ្ឌភាពសាធារណៈ ។ ...<br>- **មាត្រា៧១.** គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវចៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត ។...<br>- **មាត្រា៧២.** មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ មិនត្រូវ ៖ ...<br>- **មាត្រា៧៩.** ហាមប្រើប្រាស់ថវិកា សម្ភារ មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោត...<br>- **មាត្រា១១៨.** មិនអនុញ្ញាតឲ្យជនណាម្នាក់ចូលទៅជ្រៀតជ្រែក ឬជួយអ្នកបោះឆ្នោត ក្នុងពេលដែលអ្នកបោះឆ្នោតស្ថិតនៅក្នុងបរិវេណខាងក្នុង ឬក្នុងការិយាល័យបោះឆ្នោតបានឡើយ លើកលែងតែមានការអនុញ្ញាតអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ |
| សេចក្តីណែនាំស្តីពីការលើកស្លាកសញ្ញាគណបក្សនយោបាយ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០១៧ | - **ចំណុច២:** ការលើកស្លាកសញ្ញាគណបក្សនយោបាយ នៅទីសាធារណៈត្រូវឈរលើគោលការណ៍ ស្មើភាពលំដាប់មុនក្រោយ និងលើកស្លាកនៅលំនៅឋានឯកជន ឬទីកន្លែងឯកជនត្រូវមានការយល់ព្រមពីម្ចាស់កន្លែងនោះ ។ |
| សេចក្តីជូនដំណឹងក្រសួងមហាផ្ទៃលេខ៣១៦សជណថ្ងៃទី០៧-កុម្ភៈ-២០២២ | - ស្តីពីការបង្កលក្ខណៈងាយស្រួលដល់គ្រប់គណបក្សនយោបាយ ធ្វើសកម្មភាពចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ដូចជាៈ ការលើកស្លាកសញ្ញាគណបក្ស និងការជួបប្រជុំនយោបាយ ។ |
| សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ានឆ្នាំ២០១២ | - **មាត្រា២៥:** សិទ្ធិចូលរួមក្នុងជីវភាពនយោបាយ នៃប្រទេសជាតិរបស់ខ្លួន ។ |
| យន្តការពិនិត្យជាសកលតាមកាលកំណត់ជុំទី៣ (UPR-2019) | - **ប្រទេសន័រវែស:** បានផ្តល់អនុសាសន៍ប្រទេសកម្ពុជា ស្តារឡើងវិញនូវលំហប្រជាធិបតេយ្យ និងនយោបាយ ដោយធានានូវការចូលរួមសំរាប់គណបក្សនយោបាយផ្សេងៗ សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ។ |

## VII. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការរឹតត្បិតសេរីភាពនយោបាយ កាន់តែមានការកើនឡើងគួរឲ្យកត់សម្គាល់បើធៀបនឹងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០១៧ ដែលជាចំណុចព្រួយបារម្ភចំពោះការធ្លាក់ចុះលទ្ធិប្រជាធិបតេយ្យ - នីតិរដ្ឋ និងការអនុវត្តន៍គោលដៅអភិវឌ្ឍន៍ ប្រកបដោយចេរភាព ។ ក្នុងអំឡុងពេលបីត្រីមាស(៩ខែ)គិតចាប់ពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២២នេះ សមាគមអាដហុកបានរកឃើញ ភាពមិនប្រក្រតីជាច្រើនពាក់ព័ន្ធសិទ្ធិសេរី

ភាព របស់ប្រជាពលរដ្ឋក្នុងការចូលរួមជីវភាពនយោបាយ និងសិទ្ធិសេរីភាពក្នុងការធ្វើនយោបាយមានភាព ផ្ទុយគ្នាជាមួយការអនុវត្តន៍ច្បាប់ និងក្របខណ្ឌគតិយុត្តិជាធរមានពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចថ្នាក់ក្រោមជាតិ ។ អាជ្ញាធរមូលដ្ឋានបានប្រើគ្រប់រូបភាពគ្រប់វិធីសាស្ត្រ ដើម្បីគំរាមកំហែង លួងលោមបញ្ចុះបញ្ចូល បំភិតបំភ័យ និងរើសអើង ចំពោះអ្នកមាននិន្នាការនយោបាយផ្ទុយ ពិសេសសកម្មជនគណបក្សប្រឆាំងដែលប្រការនេះ ធ្វើឲ្យពួកគេបាក់ស្បាតលែងហ៊ានចូលរួមជីវភាពនយោបាយដូចជាៈ គំរាមឲ្យលាឈប់ពីបញ្ជីឈ្មោះបេក្ខភាពគណបក្ស បដិសេធ និងលុបឈ្មោះចេញពីបញ្ជីបេក្ខភាពគណបក្ស គំរាមកំហែងតាមរយៈប្រព័ន្ធតុលាការ មិនផ្តល់ប័ណ្ណក្រីក្រ កាត់ផ្តាច់ប្រាក់ឧបត្ថមជនក្រីក្រប្រចាំខែ កាត់ផ្តាច់អាហារូបករណ៍ មិនផ្តល់ប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុ និងការធ្វើទុក្ខបុកម្នេញផ្សេងៗទៀតជាដើម ។

ដោយមើលឃើញថា ការអនុវត្តន៍សកម្មភាពជាក់ស្តែងទាំងនេះ មិនទាន់បានដើរស្របទៅនិងគោលការណ៍ច្បាប់ និងបទដ្ឋានគតិយុត្តិជាតិ អន្តរជាតិ ក៏ដូចជាយន្តការសិទ្ធិមនុស្ស ។ ដូច្នេះ ដើម្បីចូលរួមក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋក្នុងប្រទេសកម្ពុជា ជាពិសេសការធានាបាននូវសេរីភាពក្នុងការចូលរួមសកម្មខាងនយោបាយរបស់ពលរដ្ឋឲ្យស្របតាមរដ្ឋធម្មនុញ្ញ សមាគមអាដហុកមានអនុសាសន៍មួយចំនួនសំរាប់ជាមូលដ្ឋានក្នុងការពិចារណាដូចខាងក្រោម ៖

1. ដាក់ទោសទណ្ឌតាមច្បាប់ ជាធរមានចំពោះជនណា ឬអាជ្ញាធរមូលដ្ឋានណា ដែលអនុវត្តមិនបានត្រឹមត្រូវតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាននានា ។
2. គណកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)ត្រូវដោះស្រាយនូវរាល់វិវាទពាក់ព័ន្ធកើតមានឡើងដោយឈរលើគោលការណ៍ ឯករាជ្យ អព្យាក្រឹត្យ និងដោយមិនរើសអើងបក្សនយោបាយ ។ ចំពោះវិវាទទាក់ទងការបោះឆ្នោត គប្បីត្រូវតែដោះស្រាយដោយយកច្បាប់បោះឆ្នោតជាគោល ។
3. គណកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ពង្រឹងសមត្ថភាព មន្ត្រីមូលដ្ឋានថ្នាក់ក្រោមជាតិ អំពីនីតិវិធីការបោះឆ្នោតការដោះស្រាយវិវាទ ច្បាប់ បទដ្ឋានគតិយុត្តិពាក់ព័ន្ធការបោះឆ្នោត និងក្រមសិលធម៌មន្ត្រីរាជការ ។
4. ក្រសួងមហាផ្ទៃធ្វើសេចក្តីណែនាំមន្ត្រីមូលដ្ឋានថ្នាក់ក្រោមជាតិ ឲ្យបញ្ឈប់រាល់សកម្មភាព រំខាន-បំភិតបំភ័យ គំរាមកំហែងតាមគ្រប់រូបភាព និងគ្រប់ទម្រង់ដែលអាចបង្ហាញជាសញ្ញាបំភិតបំភ័យចំពោះសកម្មជនគណបក្សនយោបាយ និងអ្នកដែលមានមតិផ្ទុយ ក៏ដូចជា ប្រជាពលរដ្ឋអ្នកបោះឆ្នោត ។
5. គណកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយ ជាពិសេសនៅតាមទីជនបទ-ជនជាតិដើមភាគតិច អំពីការពិនិត្យឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត និងឯកសារពាក់ព័ន្ធនានា សំរាប់ការបោះឆ្នោត ។
6. គណកម្មាធិការរៀបចំការបោះឆ្នោតជាតិ ចេញសេចក្តីណែនាំដល់មន្ត្រីទទួលខុសត្រូវ តាមមណ្ឌលបោះឆ្នោត ការិយាល័យបោះឆ្នោតមានតម្លាភាព ក្នុងការរាប់សន្លឹកឆ្នោត ដូចជាបិទប្រកទីតាំងការិយាល័យ និង/ឬ បិទទ្វារបង្អួចការិយាល័យរាប់សន្លឹកឆ្នោត ហើយមិនអនុញ្ញាតឱ្យប្រជាពលរដ្ឋមើលការរាប់សន្លឹកឆ្នោត ។

7. ក្រសួងមហាផ្ទៃត្រូវត្រួតពិនិត្យ និងដោះស្រាយជាបន្ទាន់ ឲ្យបញ្ឈប់ការរើសអើងគ្រប់ទម្រង់ គណបក្សនយោបាយដែលបានជាប់ឆ្នោត ដោយរៀបចំឲ្យបេក្ខជនជាប់ឆ្នោត គ្រប់គណបក្សនយោបាយអាចចូលបំពេញតួនាទី ភារៈកិច្ច តាមច្បាប់កំណត់។
8. ក្រសួងយុត្តិធម៌ពង្រឹងយុត្តិធម៌សង្គម លុបបំបាត់អំពើ និទណ្ឌភាពគ្រប់ទម្រង់ ជាពិសេសអំពើល្មើសដែលប្រព្រឹត្តឡើងក្នុងគោលដៅនយោបាយ ដូចជា ការបង្ករបួសស្នាមសកម្មជននយោបាយ និងការធ្វើទុក្ខបុកម្និញ សកម្មជននយោបាយតាមប្រព័ន្ធតុលាការ ។

# V. ឧបសម្ព័ន្ធ

| ល.រ | ករណី | ខេត្ត | | | | | | | | | | | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ត្បូងឃ្មុំ | កំពង់ចាម | ប៉ៃលិន | បាត់ដំបង | កំពង់ស្ពឺ | សៀមរាប | ឧត្តរមានជ័យ | ស្ទឹងត្រែង | ពោធិសាត់ | ស្វាយរៀង | ក្រចេះ | កំពត | កោះកុង | កំពង់ធំ | ព្រះវិហារ | ស៊ីហនុ | ព្រៃវែង | |
| ១ | វៃតឡិតសេរីភាពជួបជុំសកម្មជនគណបក្ស | 1 | | | | 1 | | | 1 | | | | | | | | | | 3 |
| ២ | **រារាំងការលើកស្លាកសញ្ញាគណបក្ស** | 6 | 2 | 2 | 1 | | 6 | 1 | | | 1 | | | | | | 1 | | 20 |
| ៣ | បំផ្លាញស្លាកសញ្ញាគណបក្ស | 3 | 1 | | | | 1 | | 4 | | 2 | | | | 1 | | 2 | | 14 |
| ៤ | គំរាមឲ្យលាឈប់ពីបញ្ជីឈរឈ្មោះបេក្ខភាពគណបក្ស ( * ) | 1 | 4 | 2 | 5 | 1 | 4 | 6 | 2 | | 3 | 1 | 1 | 1 | 1 | 1 | 1 | 1 | 35 |
| ៥ | គំរាម( តាមបណ្ដាញសង្គម )-បង្ករបួសស្នាម | | | 1 | | | | 2 | | | | | | | | | | | 3 |
| ៦ | បដិសេធនិងលុបឈ្មោះចេញពីបញ្ជីបេក្ខភាពគណបក្ស | | | 1 | | | | | | | | | | | | | | | 1 |
| ៧ | គំរាមកំហែងតាមរយៈប្រព័ន្ធតុលាការ | | | | | | | 1 | 1 | 2 | | | | | | | | 1 | 5 |
| **សរុបចំនួនករណី (ខេត្ត)** | | **11** | **7** | **6** | **6** | **2** | **11** | **10** | **8** | **2** | **6** | **1** | **1** | | | | **4** | **2** | **81** |

*( * ) ១ករណីអាចមានចំនួនសមនុស្សចាប់ពី០១នាក់រហូតដល់០៧នាក់ (សរុបៈ៤៥នាក់)*

| ល.រ | ចំនួន | ត្បូងឃ្មុំ | កំពង់ចាម | ប៉ៃលិន | បាត់ដំបង | កំពង់ស្ពឺ | សៀមរាប | ឧត្តរមានជ័យ | ស្ទឹងត្រែង | ពោធិសាត់ | ស្វាយរៀង | ក្រចេះ | កំពត | កោះកុង | ស៊ីហនុ | ព្រៃវែង | កំពង់ធំ | ព្រះវិហារ | Total |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ចំនួនខេត្ត | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 17 |
| ២ | ចំនួនស្រុក-ក្រុង | 7 | 5 | 2 | 5 | 1 | 6 | 4 | 4 | 2 | 4 | 1 | 1 | 1 | 3 | 1 | 2 | 1 | 50 |
| ៤ | ចំនួនឃុំ-សង្កាត់ | 10 | 7 | 3 | 4 | 1 | 3 | 8 | 6 | 2 | 5 | 1 | 1 | 1 | 3 | 2 | 2 | 1 | 60 |

សរុបករណី៨១ (១៧ខេត្ត-៥០ស្រុក-៦០ឃុំ)





ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

-----------------

ពាក្យបណ្តឹង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ [redacted] អាយុ [illegible] ឆ្នាំ ជា [illegible] មុខរបរ [illegible]

រស់នៅភូមិ [illegible] ឃុំ [illegible] ស្រុក [illegible] ខេត្ត [illegible] លេខទូរស័ព្ទ 096 5772257

សូមគោរពជូន

លោកប្រធានសមាគមអាដហុកខេត្តកំពង់ឆ្នាំង

កម្មវត្ថុ៖ [illegible] [redacted]

មូលហេតុ៖ [illegible] 2022 [illegible] 2022 [illegible] ។

អាស្រ័យហេតុនេះសូមលោកប្រធានមេត្តាជួយរកយុត្តិធម៌និងអន្តរាគមន៍ដល់រូបខ្ញុំបាទ/នាងខ្ញុំ ដោយក្តីអនុគ្រោះ ។

សូមលោកប្រធានមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ ។

កំពង់ឆ្នាំងថ្ងៃទី 17 ខែ [illegible] ឆ្នាំ២០22

ស្នាមមេដៃ

[redacted]



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពាក្យបណ្តឹង

យើងខ្ញុំជាប្រជាពលរដ្ឋចំនួន 3 គ្រួសារចំនួន 9 នាក់ស្រីចំនួន 3 នាក់ជនជាតិ [illegible] សញ្ជាតិខ្មែរ

អាស័យដ្ឋានបច្ចុប្បន្ននៅភូមិ [illegible] ឃុំ [illegible] ស្រុក [illegible] ខេត្តស្ទឹងត្រែង។

លេខទូរស័ព្ទ៖ 0612199077

សូមគោរពជូន

លោកប្រធាន នៃសមាគមអាដហុកប្រចាំខេត្តស្ទឹងត្រែង

កម្មវត្ថុ៖ [illegible] ។

តបតាមកម្មវត្ថុខាងលើយើងខ្ញុំ សូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា៖ [illegible] 2022 [illegible] 11:00 [illegible] ។

អាស្រ័យដូចបានជម្រាបជូនខាងលើយើងខ្ញុំសូម **លោកប្រធាន** មេត្តាជួយស៊ើបអង្កេតស្វែងរកការពិត និងអន្តរាគមន៍ទៅស្ថាប័នជួពាក់ព័ន្ធ ដើម្បីផ្តល់យុត្តិធម៌ដល់យើងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ធ្វើនៅ [illegible] ថ្ងៃទី 09 ខែ 03 ឆ្នាំ២០22

ស្នាមម្រាមដៃស្តាំអ្នកប្តឹង

[redacted] [redacted] [redacted]